ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ០៣៥ ស.ជ.ណ

# សេចក្តីណែនាំ
## ស្តីពី
## ការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន

តាមរយៈការសិក្សាផ្ទៀងផ្ទាត់ទិន្នន័យប្រជាពលរដ្ឋនាពេលកន្លងមក ក្រសួងមហាផ្ទៃបានកត់សម្គាល់ឃើញថា ប្រជាពលរដ្ឋប្រមាណជិត៣៥ភាគរយកំពុងជួបប្រទះបញ្ហាខុសទិន្នន័យអត្តសញ្ញាណរបស់ខ្លួននៅក្នុងបញ្ជីនិងសំបុត្រអត្រានុកូលដ្ឋាន ជាមួយឯកសារអត្តសញ្ញាណដទៃទៀត និងប្រជាពលរដ្ឋខ្លះបានចុះបញ្ជីអត្រានុកូលដ្ឋានប្រភេទតែមួយលើសពីមួយដង ជាពិសេសការចុះបញ្ជីក្នុងអំឡុងពេលយុទ្ធនាការចុះបញ្ជីអត្រានុកូលដ្ឋានចល័ត ដែលបានធ្វើឱ្យសាមីខ្លួនជួបការលំបាកយ៉ាងខ្លាំងក្នុងការស្នើសុំសេវារដ្ឋបាលផ្សេងៗ។ រីឯនីតិវិធីក្នុងការកែតម្រូវនិងការមោឃភាពបញ្ជីអត្រានុកូលដ្ឋានបច្ចុប្បន្នមានភាពលំបាកស្មុគស្មាញដែលមិនអាចឆ្លើយតបបានទៅនឹងសំណូមពររបស់ប្រជាពលរដ្ឋ។

យោងតាមអនុក្រឹត្យលេខ១៣៨អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ បានផ្តល់សមត្ថកិច្ចមួយចំនួនដល់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ក្នុងការពិនិត្យសម្រេចនិងអនុញ្ញាតឱ្យកែតម្រូវទិន្នន័យអត្រានុកូលដ្ឋាន ឬអនុញ្ញាតឱ្យចុះបញ្ជីអត្រានុកូលដ្ឋានឡើងវិញស្របតាមបទប្បញ្ញត្តិច្បាប់។ អនុវត្តតាមស្មារតីនៃអនុក្រឹត្យនេះ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំអំពីការកែតម្រូវ និងការធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ដើម្បីដោះស្រាយការលំបាកចំពោះមុខរបស់ប្រជាពលរដ្ឋ ដូចខាងក្រោម៖

### I. អំពីទិន្នន័យដែលអាចកែតម្រូវបាន

ទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានអាចកែតម្រូវបាន គឺជាទិន្នន័យដែលបានសរសេរខុសព័ត៌មានដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ មានដូចខាងក្រោម៖

១. ការខុសឆ្គងអក្ខរាវិរុទ្ធលើ នាមត្រកូល និង/ឬនាមខ្លួនជា "អក្សរខ្មែរ" និង"អក្សរឡាតាំង" របស់សាមីខ្លួន ឬរបស់ឪពុក ឬរបស់ម្តាយ (មានន័យថាសូរសំឡេងដូចគ្នា ឬប្រហាក់ប្រហែលគ្នាប៉ុន្តែការសរសេរខុសគ្នា)។

២. ការសរសេរខុស "ភេទ" នៅពេលចុះបញ្ជី ដូចជា ភេទ "ប្រុស" តែសរសេរដាក់ថាភេទ "ស្រី" ឬភេទ "ស្រី" តែសរសេរដាក់ថាភេទ "ប្រុស"។

៣. អាយុរបស់ឪពុក ឬម្តាយ តិចជាងឬតំណាលគ្នានឹងអាយុកូនដែលមិនសមនឹងកើតមាន ឬការចុះថ្ងៃឆ្នាំកំណើតច្រឡំ ដូចជា កើតឆ្នាំ១៩៧៥ ដាក់ថាឆ្នាំ១៩៥៧។

៤. ខុសថ្ងៃកំណើតសុរិយគតិ (ដូចជាថ្ងៃទី៣០ ខែកុម្ភៈ ឬថ្ងៃទី៣១ ខែមេសា)។

៥. ខុសថ្ងៃកំណើតច័ន្ទគតិ ដូចជាសរសេរចុះដាក់ថ្ងៃច័ន្ទ ទី១៣ ខែមេសា ឆ្នាំ១៩៧២ ប៉ុន្តែជាក់ស្តែងថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧២ ជាថ្ងៃព្រហស្បតិ៍។

៦. ការកាន់ច្រឡំទីតាំងភូមិសាស្ត្ររដ្ឋបាល ដូចជាសរសេរដាក់ថា ស្រុកកំពង់សៀម ខេត្តកំពង់ស្ពឺ ប៉ុន្តែជាក់ស្តែងស្រុកកំពង់សៀម ស្ថិតក្នុងខេត្តកំពង់ចាម។

៧. ខ្វះទីកន្លែងកំណើត បានសរសេរខុសពីទីកន្លែងកំណើតដែលសាមីខ្លួនបានកើតជាក់ស្តែង ឬ សរសេរខុសទីតាំងភូមិសាស្ត្ររដ្ឋបាលនាសម័យដែលបុគ្គលនោះកើត ឧទាហរណ៍ បញ្ជីកំណើតរបស់បុគ្គលម្នាក់បានចុះថា កើតឆ្នាំ១៩៨៥ នៅស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ប៉ុន្តែ ក្នុងអំឡុងឆ្នាំ១៩៨៥ ស្រុកមង្គលបុរី ស្ថិតនៅក្នុងខេត្តបាត់ដំបង ពីព្រោះមិនទាន់បង្កើតខេត្តបន្ទាយមានជ័យនៅឡើយ។

៨. ការខកខានមិនបានចុះព័ត៌មាននៅក្នុងបញ្ជីអត្រានុកូលដ្ឋាន លើកលែងតែការបន្ថែមទិន្នន័យព័ត៌មានណាដែលធ្វើឱ្យសាមីខ្លួនរួចផុតពីការទទួលខុសត្រូវខាងផ្លូវច្បាប់។

៩. សម្រេចមោឃភាពលើបញ្ជីអត្រានុកូលដ្ឋានទាំងឡាយណាដែលបានចុះជាន់គ្នា។

១០. កែតម្រូវទិន្នន័យអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចរបស់តុលាការ។

## II. អំពីសមត្ថកិច្ច

១. ក្នុងឆ្នាំកំពុងអនុវត្ត ការកែតម្រូវទិន្នន័យនិងការធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋានជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់។

២. ក្នុងឆ្នាំកន្លងផុត ការកែតម្រូវទិន្នន័យនិងការធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋានជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

៣. ករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិមិនអាចសម្រេចកែតម្រូវទិន្នន័យព័ត៌មានដូចមានចែងក្នុងចំណុច"ក"ខាងលើ ឬការកែតម្រូវទិន្នន័យដែលមិនមែនជាសមត្ថកិច្ចរបស់ខ្លួន ត្រូវជូនទៅតុលាការជាសមត្ថកិច្ច។

## III. អំពីនីតិវិធី

### ក. ការកែតម្រូវ

#### ១. សម្រាប់ឆ្នាំកំពុងអនុវត្ត

សាមីជន ឬអាណាព្យាបាល ឬញាតិជានីតិជនដែលរស់នៅក្នុងផ្ទះជាមួយ អាចដាក់ពាក្យសុំកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋានទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៅសាលាឃុំ សង្កាត់ ក្នុងករណីពិនិត្យឃើញថាសំបុត្រអត្រានុកូលដ្ឋានរបស់ខ្លួនបានសរសេរទិន្នន័យព័ត៌មានមួយចំនួនខុស។

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ត្រូវកែតម្រូវបញ្ជីអត្រានុកូលដ្ឋានរបស់អ្នកដាក់ពាក្យសុំ ស្របតាមការណែនាំនៅក្នុងកម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន។

#### ២. សម្រាប់ឆ្នាំកន្លងផុត

*២.១. ការដាក់ពាក្យសុំ*

សាមីខ្លួន ឬអាណាព្យាបាល ឬញាតិជានីតិជនដែលរស់នៅក្នុងផ្ទះជាមួយ អាចដាក់ពាក្យទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ដើម្បីសុំកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋាន( ឧបសម្ព័ន្ធ១ )នៅ៖

- នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ។៤ ·៤

- សាលាក្រុង ស្រុក ខណ្ឌ នៃទីតាំងដែលបញ្ជីអត្រានុកូលដ្ឋានរបស់សាមីខ្លួនបាននិងកំពុងរក្សាទុក។ ទទួលបានពាក្យសុំ សាលាក្រុង ស្រុក ខណ្ឌត្រូវបញ្ជូនសំណុំឯកសារពាក់ព័ន្ធមកនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ យ៉ាងយូរ០៣(បី)ថ្ងៃការងារ។

## ៦.២. ឯកសារភ្ជាប់

- សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និង/ឬសេចក្ដីចម្លងសំបុត្រអត្រានុកូលដ្ឋានទាំងអស់
- សៀវភៅស្នាក់នៅ និង/ឬសៀវភៅគ្រួសារ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ(អាយុចាប់ពី១៥ឆ្នាំឡើង) ឬ
- លិខិតឆ្លងដែន បើមាន
- ឯកសារពាក់ព័ន្ធផ្សេងៗដូចជាប័ណ្ណសំគាល់ខ្លួនមន្ត្រីរាជការ អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ ។ល។

រាល់ឯកសារភ្ជាប់ត្រូវថតចម្លងដោយមានបញ្ជាក់នីត្យានុកូលភាពត្រឹមត្រូវ លើកលែងសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និងសេចក្ដីចម្លងសំបុត្រអត្រានុកូលដ្ឋានទាំងអស់។

## ៦.៣. ការសម្រេចកែតម្រូវរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

នាយកដ្ឋានអត្រានុកូលដ្ឋានត្រូវធ្វើជាសេនាធិការជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ក្នុងការពិនិត្យលើទិដ្ឋភាពច្បាប់នៃឯកសារពាក់ព័ន្ធ និងមូលហេតុនៃការស្នើសុំកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋាន។ ក្នុងករណីចាំបាច់នាយកដ្ឋានអត្រានុកូលដ្ឋានអាចស្រាវជ្រាវបន្ថែមអំពីមូលហេតុនៃការស្នើសុំកែតម្រូវបញ្ជីអត្រានុកូលដ្ឋាននេះបាន។

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិត្រូវចេញសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមថ្មី០១(មួយ)ច្បាប់ ដោយចុះកាលបរិច្ឆេទថ្មីទៅតាមពេលវេលាជាក់ស្តែងដែលចេញសំបុត្រអត្រានុកូលដ្ឋាននោះរួចដកហូតនិងមោឃៈនូវសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមចាស់និងសេចក្ដីចម្លងសំបុត្រអត្រានុកូលដ្ឋានដែលខុសទាំងអស់។

ការស្នើសុំកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋានត្រូវពិនិត្យសម្រេច៖

- មិនឱ្យលើសរយៈពេល១០(ដប់)ថ្ងៃការងារ ចំពោះពាក្យស្នើសុំកែតម្រូវដែលដាក់នៅនាយកដ្ឋានអត្រានុកូលដ្ឋាននៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និង
- មិនឱ្យលើសរយៈពេល២០ថ្ងៃការងារចំពោះពាក្យស្នើសុំកែតម្រូវដែលដាក់នៅសាលាក្រុង ស្រុក ខណ្ឌ។

សេចក្តីសម្រេចកែតម្រូវត្រូវធ្វើឡើងចំនួន០៤(បួន)ច្បាប់ ក្នុងនោះ៖

- ០១(មួយ)ច្បាប់សម្រាប់បញ្ជូនទៅនាយកដ្ឋានអត្រានុកូលដ្ឋាន ដើម្បីកិបភ្ជាប់បញ្ជីអត្រានុកូលដ្ឋានដែលកំពុងរក្សាទុកនៅទីនោះ
- ០១(មួយ)ច្បាប់សម្រាប់ចម្លងជូនសាលារាជធានី ខេត្ត
- ០១(មួយ)ច្បាប់សម្រាប់បញ្ជូនទៅសាលាក្រុង ស្រុក ខណ្ឌ ដើម្បីកិបភ្ជាប់នឹងបញ្ជីអត្រានុកូលដ្ឋានដែលកំពុងរក្សាទុកនៅទីនោះ និង
- ០១(មួយ)ច្បាប់សម្រាប់សាមីខ្លួន។

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិអាចសម្រេចបដិសេធមិនឱ្យកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានតាមការស្នើសុំបាន ដោយមានបញ្ជាក់អំពីមូលហេតុជាក់លាក់។ ករណីនេះសាមីខ្លួនអាចប្តឹងជំទាស់ទៅតុលាការបាន។៤ ·

## ខ. ការធ្វើមោឃភាព

### ១. សម្រាប់ឆ្នាំកំពុងអនុវត្ត

ការធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋាននៅក្នុងឆ្នាំកំពុងអនុវត្ត មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ត្រូវអនុវត្តស្របតាមការណែនាំនៅក្នុងកម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន។

### ២. សម្រាប់ឆ្នាំកន្លងផុត

នាយកដ្ឋានអត្រានុកូលដ្ឋានត្រូវធ្វើជាសេនាធិការជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ក្នុងការពិនិត្យសម្រេចលើការធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋានទាំងឡាយណាដែលៈ

- ចុះបញ្ជីផ្ទុយពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន
- ចុះបញ្ជីអត្រានុកូលដ្ឋានលើសពី០១(មួយ)ដង នៅកន្លែងដដែល ឬនៅកន្លែងផ្សេងទៀត។

ករណីរកឃើញបញ្ហាដូចខាងលើនេះ នាយកដ្ឋានអត្រានុកូលដ្ឋានត្រូវជូនដំណឹងដល់សាមីខ្លួន ឬអាណាព្យាបាល តាមរយៈអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ដើម្បីឱ្យដាក់ពាក្យសុំធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋានដែលបានចុះលើសពី០១ដងនោះ ដើម្បីធ្វើការជ្រើសរើសយកបញ្ជីណាមួយដែលជាទិន្នន័យត្រឹមត្រូវដើម្បីប្រើប្រាស់ជាផ្លូវការ។

ករណីដែលសាមីខ្លួនឬអាណាព្យាបាលមិនព្រមមកដាក់ពាក្យសុំធ្វើមោឃភាពបញ្ជីណាមួយ ក្នុងអំឡុងពេល៦០(ហុកសិប)ថ្ងៃចាប់ពីទទួលបានលិខិតជូនដំណឹង មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិមានសិទ្ធិចេញសេចក្តីសម្រេចធ្វើមោឃភាពសំបុត្រអត្រានុកូលដ្ឋាននិងបញ្ជីអត្រានុកូលដ្ឋានដែលបានចុះកាលបរិច្ឆេទមុន ដោយរក្សាទុកសំបុត្រអត្រានុកូលដ្ឋាន និងបញ្ជីអត្រានុកូលដ្ឋានដែលបានចុះកាលបរិច្ឆេទក្រោយ។

សេចក្តីសម្រេចធ្វើមោឃភាពត្រូវធ្វើឡើងចំនួន០៤(បួន)ច្បាប់ ក្នុងនោះៈ

- ០១(មួយ)ច្បាប់សម្រាប់បញ្ជូនទៅនាយកដ្ឋានអត្រានុកូលដ្ឋាន ដើម្បីកិបភ្ជាប់បញ្ជីអត្រានុកូលដ្ឋានដែលកំពុងរក្សាទុកនៅទីនោះ
- ០១(មួយ)ច្បាប់សម្រាប់ចម្លងជូនសាលារាជធានី ខេត្ត
- ០១(មួយ)ច្បាប់សម្រាប់បញ្ជូនទៅសាលាក្រុង ស្រុក ខណ្ឌ ដើម្បីកិបភ្ជាប់នឹងបញ្ជីអត្រានុកូលដ្ឋានដែលកំពុងរក្សាទុកនៅទីនោះ និង
- ០១(មួយ)ច្បាប់សម្រាប់សាមីខ្លួន។

សាមីខ្លួនអាចធ្វើការតវ៉ាពីការសម្រេចនេះ មកមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលសេចក្តីសម្រេចធ្វើមោឃភាពនេះ។

## គ. ការអនុវត្តការងាររបស់មន្ត្រីរក្សាសៀវភៅ

បន្ទាប់ពីទទួលបានសេចក្តីសម្រេចពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ និងមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅសាលាក្រុង ស្រុក ខណ្ឌ ត្រូវៈ

- កិបភ្ជាប់សេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ នៅគល់បញ្ជីអត្រានុកូលដ្ឋានដែលត្រូវធ្វើការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន

ឧបសម្ព័ន្ធទី១

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### ពាក្យស្នើសុំកែតម្រូវទិន្នន័យអត្រានុកូលដ្ឋាន

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................. កើតថ្ងៃទី........ ខែ......... ឆ្នាំ............ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.......... ផ្លូវ......... ក្រុមទី.......... ភូមិ.....................ឃុំ សង្កាត់.......................................... ក្រុង ស្រុក ខណ្ឌ.........................រាជធានី ខេត្ត..........................ត្រូវជា[១]..................................។

**សូមគោរពជូន**

**ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**
**និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ**

**កម្មវត្ថុ** : សំណើសុំកែតម្រូវទិន្នន័យអត្រានុកូលដ្ឋាន..........................................................................។
**យោង** : [២].......................................................................................................................................

.......................................................................................................................................

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ** មេត្តាជ្រាបថា សំបុត្រអត្រានុកូលដ្ឋាន.................................................. ដែលចុះហត្ថលេខាដោយលោកស្រី/លោក.........................................................ជាមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់...........................នៅក្នុងសៀវភៅអត្រានុកូលដ្ឋាន.................................................... លេខ............... ឆ្នាំ................ ត្រង់បញ្ជីលេខ........................ របស់ឈ្មោះ.................................. ភេទ ..........កើតនៅថ្ងៃទី........ខែ............ឆ្នាំ................ [៣] និងរបស់ឈ្មោះ........................ ភេទ ........ កើតនៅថ្ងៃទី....... ខែ....... ឆ្នាំ........... មានកំហុសឆ្គងទិន្នន័យមួយចំនួនមិនអាចប្រើប្រាស់បាន។ ដូចនេះ ខ្ញុំបាទ នាងខ្ញុំ គោរពស្នើសុំធ្វើការកែតម្រូវទិន្នន័យក្នុងបញ្ជីអត្រានុកូលដ្ឋានដូចខាងក្រោម៖

ពី............................................. ទៅ .............................................................
ពី............................................. ទៅ .............................................................
ពី............................................. ទៅ .............................................................

ជំនួសវិញ។

ខ្ញុំបាទ/នាងខ្ញុំ សូមសន្យាថានឹងទទួលខុសត្រូវនូវរាល់ព្យសនកម្មនានា ដែលកើតឡើងពីការសុំកែតម្រូវខាងលើនេះចំពោះមុខច្បាប់ជាធរមាន។

អាស្រ័យហេតុនេះ សូម ឯកឧត្តម អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ មេត្តាធ្វើការកែតម្រូវទិន្នន័យក្នុងបញ្ជីអត្រានុកូលដ្ឋានតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ.................. ថ្ងៃទី............ ខែ.......... ឆ្នាំ២០....

ស្នាមមេដៃសាមីខ្លួន/អាណាព្យាបាល/ញាតិ

លេខ:......................

បានឃើញ និងគោរពជូនឯកឧត្តម អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ មេត្តាពិនិត្យសម្រេច ដ៏ខ្ពង់ខ្ពស់។

ថ្ងៃទី.............ខែ.....................ឆ្នាំ.........

**ប្រធាននាយកដ្ឋាន/អភិបាលក្រុង ស្រុក ខណ្ឌ**

**កំណត់ចំណាំ:**

[១] ត្រូវជាសាមីខ្លួន អាណាព្យាបាល ឬញាតិ
[២] ឯកសារដូចមាននៅខាងខ្នងនៃពាក្យសុំ
[៣]ករណីសំបុត្រអាពាហ៍ពិពាហ៍

ឧបសម្ព័ន្ធទី២

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យស្នើសុំមោឃភាពបញ្ជីអត្រានុកូលដ្ឋាន

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................. កើតថ្ងៃទី........ ខែ......... ឆ្នាំ............ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.......... ផ្លូវ......... ក្រុមទី.......... ភូមិ....................ឃុំ សង្កាត់........................................ ក្រុង ស្រុក ខណ្ឌ.........................រាជធានី ខេត្ត..........................ត្រូវជា(១).......................................។

**សូមគោរពជូន**

**ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**
**និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ**

**កម្មវត្ថុ** : សំណើសុំមោឃភាពបញ្ជីអត្រានុកូលដ្ឋាន.......................................................................។
**យោង** : (២)..........................................................................................................................
..........................................................................................................................

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ** មេត្តាជ្រាបថា សំបុត្រអត្រានុកូលដ្ឋាន............................................ ដែលចុះហត្ថលេខាដោយលោកស្រី/លោក.................................................... ជាមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់..........................នៅក្នុងសៀវភៅអត្រានុកូលដ្ឋាន.......................................... លេខ............... ឆ្នាំ................ ត្រង់បញ្ជីលេខ....................... របស់ឈ្មោះ.................................. ភេទ..........កើតនៅថ្ងៃទី........ខែ............ឆ្នាំ....................(៣) និងរបស់ឈ្មោះ....................... ភេទ ........ កើតនៅថ្ងៃទី....... ខែ....... ឆ្នាំ...........បានអនុវត្តមិនស្របតាមនីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាននោះ ដោយសារ..............................................................................................................................
..............................................................................................................................។

ខ្ញុំបាទ/នាងខ្ញុំ សូមសន្យាថានឹងទទួលខុសត្រូវនូវរាល់ព្យសនកម្មនានា ដែលកើតឡើងពីការធ្វើមោឃភាពខាងលើនេះចំពោះមុខច្បាប់ជាធរមាន។

អាស្រ័យហេតុនេះ សូម ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ មេត្តាពិនិត្យសម្រេចមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ................... ថ្ងៃទី......... ខែ.............. ឆ្នាំ២០....
ស្នាមមេដៃសាមីខ្លួន/អាណាព្យាបាល/ញាតិ

លេខ:.....................
បានឃើញ និងគោរពជូនឯកឧត្តម អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ មេត្តាពិនិត្យសម្រេច ដ៏ខ្ពង់ខ្ពស់។
ថ្ងៃទី.............ខែ.....................ឆ្នាំ.........
**ប្រធាននាយកដ្ឋាន/អភិបាលក្រុង ស្រុក ខណ្ឌ**

កំណត់ចំណាំ:

(១) ត្រូវជាសាមីខ្លួន អាណាព្យាបាល ឬញាតិ
(២) ឯកសារដូចមាននៅខាងខ្នងនៃពាក្យសុំ
(៣) ករណីសំបុត្រអាពាហ៍ពិពាហ៍

ឧបសម្ព័ន្ធទី៣

បញ្ជីអត្រានុកូលដ្ឋាននេះបានកែតម្រូវ

"យោង..........លេខ..........ចុះថ្ងៃទី.....ខែ.....ឆ្នាំ........របស់.....................។

ថ្ងៃទី.......ខែ.........ឆ្នាំ...........

មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន

ហត្ថលេខានិងឈ្មោះ

ឧបសម្ព័ន្ធទី៨

បញ្ជីអត្រានុកូលដ្ឋាននេះអស់សុពលភាព

"យោង..........លេខ..........ចុះថ្ងៃទី.....ខែ.....ឆ្នាំ........របស់.....................។

ថ្ងៃទី.......ខែ.........ឆ្នាំ...........

មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន

ហត្ថលេខានិងឈ្មោះ